Public Health
Seattle & King County

# បទបញ្ជារបស់មន្ត្រីសុខាភិបាលក្នុងតំបន់ឃីងខោនធី

## ឥឡូវនេះ គេតម្រូវឱ្យពាក់ម៉ាស់នៅក្នុងព្រឹត្តិការណ៍នៅខាងក្រៅណាមួយដែលមានមនុស្សចំនួនពី ៥០០ នាក់ឡើងទៅចូលរួម។

បទបញ្ជានេះគឺសម្រាប់អ្នកដែលបានចាក់វ៉ាក់សាំងនិងអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង ពីអាយុ ៥ ឆ្នាំឡើងទៅ។



Public Health
Seattle & King County

ឥឡូវនេះ **គេក៏សំណូមពរយ៉ាងខ្លាំង**ឱ្យមនុស្សទាំងអស់ដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅពាក់ម៉ាស់ - ទាំងអ្នកដែលបានចាក់វ៉ាក់សាំងហើយនិងអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំង - **នៅតាមទីកន្លែងខាងក្រៅ**ណាមួយដែលមនុស្សទាំងឡាយមិនអាចរក្សាគម្លាតយ៉ាងហោចណាស់ ៦ ហ្វីតពីអ្នកដែលមិនមែនជាសមាជិកក្នុងគ្រួសារ។



Public Health
Seattle & King County

# ហេតុអ្វីបានជាមានបទបញ្ញាថ្មីឱ្យពាក់ម៉ាស់នៅតាមទីកន្លែងនៅខាងក្រៅ?

- នៅក្នុងតំបន់ King County **កំពុងតែកើនមានការឆ្លង**ជំងឺកូវីដ-១៩ យ៉ាងខ្លាំង។

- ប្រព័ន្ធថែទាំសុខភាពរបស់យើងកំពុងស្ថិតនៅក្រោមភាពតានតឹងយ៉ាងខ្លាំង។

- **មេរោគបំលែងថ្មីដែលតា (Delta)** កំពុងឆ្លងកាន់តែខ្លាំងហើយធ្វើឱ្យមានហានិភ័យខ្ពស់ក្នុងការឈឺចូលដេកព្យាបាលនៅក្នុងមន្ទីរពេទ្យ។

- អ្នកដែលបានចាក់វ៉ាក់សាំងគ្រប់ចំនួនហើយ មានកំរិតខ្ពស់ក្នុងការការពារមិនឱ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារ COVID-19 ប៉ុន្តែ**នៅតែអាចចម្លងទៅអ្នកដទៃបាន។**

Public Health
Seattle & King County

# សូមចងចាំថា គេនៅតែតម្រូវឱ្យពាក់ម៉ាស់ នៅខាងក្នុងអគារតាមទីកន្លែងសាធារណៈ។

ចាប់ពីថ្ងៃទី ២៣ ខែសីហា មនុស្សគ្រប់ៗគ្នាដែលមានអាយុចាប់ពី ៥ ឆ្នាំ ឡើងទៅនៅក្នុងរដ្ឋវ៉ាស៊ីងតោន ត្រូវពាក់ម៉ាស់នៅ**ខាងក្នុងអគារតាមទីកន្លែងសាធារណៈ**ដូចជា ហាងលក់គ្រឿងទេស ផ្សារទំនើប កន្លែងហាត់ប្រាណនិងមជ្ឈមណ្ឌលសហគមន៍។

មនុស្សគ្រប់ៗគ្នាក៏ត្រូវបន្តពាក់ម៉ាស់ដែលបិទជិតពីលើមុខ នៅក្នុងមណ្ឌលឃុំឃាំង កន្លែងជ្រកកោនសម្រាប់អ្នកគ្មានផ្ទះសម្បែង សាលារៀននិងកន្លែងថែទាំកូនក្មេង ក្នុងឡានក្រុងសាធារណៈ និងមន្ទីរថែទាំសុខភាព ដូចជាការិយាល័យវេជ្ជបណ្ឌិត មណ្ឌលថែទាំមនុស្សចាស់ជរា ហើយនិងមន្ទីរពេទ្យ។

ចំពោះព័ត៌មានបន្ថែម សូមចូលមើល

**kingcounty.gov/masks**

Public Health
Seattle & King County